ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ក១"

លេខ៖ ០៣៧/៤៩... ក១.ដ.ដ

# ដីកាលើកលែងចោទប្រកាន់

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី [redacted] ជាក្រឡាបញ្ជី ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣៧១៦ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១

-បានឃើញ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៨៧៦ អ.យ.ឃ ចុះថ្ងៃទី១១ខែកញ្ញា ឆ្នាំ២០២១របស់តំណាងរអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ២៨៤២ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១២១២ អ.យ.ឃ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ជនត្រូវចោទឈ្មោះ [redacted]ប៊ុនស្រ៊ី ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិខ្ពប ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់[redacted] ត្រពាំងឈូក ក្រុម២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted] គ្មានកូន ឪពុកឈ្មោះ [redacted](ស្លាប់) ម្តាយឈ្មោះ[redacted](រស់) ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖ធ្លាប់ជាប់ពន្ធនាគារព្រៃស(ម១) ប្រហែល ០៦ឆ្នាំ ពីបទឃាតកម្ម ជានីតិជន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៣៤៩ ឈ១.ដ.ឃ.ដ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ នៅមណ្ឌលអប់រំកែប្រែទី១(ម១)។

ក្រោយពីបានពិនិត្យ ស៊ើបសួរចប់សព្វគ្រប់ឃើញថា៖

-កាលពីថ្ងៃទីមិនចាំក្នុងខែតុលា ឆ្នាំ២០១៩ ឈ្មោះ[redacted]ប៊ុនស្រ៊ី ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ បានឱ្យកូនស្រីចុងរបស់ខ្លួនឈ្មោះ[redacted]មុន្នីនាថ ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ មកដេកនៅក្នុងបន្ទប់ជាមួយគ្រាន់បានជាគ្នានៅពេលដែលឈ្មោះ [redacted]ពុទ្ធបី ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ ត្រូវជាប្រពន្ធចុងរបស់ជននេះបានចេញទៅខេត្តសៀមរាប លុះដល់វេលាម៉ោង០១ និង០០នាទីយប់ ឈ្មោះ[redacted] ប៊ុនស្រ៊ី ក៏បានធ្វើសកម្មភាពចាប់រំលោភសេពសន្ថវៈលើជនរងគ្រោះរហូតបានសម្រេចចំនួន០១លើក ដោយមិនពាក់ស្រោមនៅចំណុចបន្ទប់លេខ៤៩ ផ្លូវលំ ភូមិត្រពាំងឈូក ក្រុម២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ សមត្ថកិច្ចកងរាជអាវុធហត្ថរាជធានីភ្នំពេញ ក៏បានធ្វើការឃាត់ខ្លួនជននេះពាក់ព័ន្ធនឹងករណីហិង្សាប្រព្រឹត្តដោយសហព័ទ្ធលើឈ្មោះ [redacted]ពុទ្ធបី, បង្ខាំងមនុស្សដោយខុសច្បាប់ និងកាប់កាប់អាវុធដោយខុសច្បាប់ ទើបជនរងគ្រោះឈ្មោះ[redacted]មុន្នីនាថ ក៏បានដាក់ពាក្យបណ្តឹងលើជននេះពីករណីរំលោភសេពសន្ថវៈលើខ្លួនកន្លងមក ដើម្បីឱ្យសមត្ថកិច្ចចាត់ការតាមច្បាប់។

-តាមចម្លើយរបស់ឈ្មោះ [redacted] មុន្នីនាថ បានឆ្លើយថាកាលពីថ្ងៃមិនចាំខែតុលា ឆ្នាំ២០១៩ វេលាម៉ោង០១យប់ ឈ្មោះ[redacted] ប៊ុនស្រ៊ីដែលត្រូវជាឪពុកចុងពិតជាបានធ្វើសកម្មភាពចាប់រំលោភមកលើខ្លួនដោយមិន[illegible]ប្រាកដមែន

នៅពេលដែលម្តាយខ្លួនទៅខេត្តសៀមរាប ហើយបានសន្យាថានឹងទិញខ្សែករ និងរថយន្តឱ្យខ្លួន ប៉ុន្តែលុះដល់អំឡុងចុងឆ្នាំ២០២០ ទើបគាត់បានទិញខ្សែករមួយខ្សែ ៧០០USD(ប្រាំពីររយដុល្លារអាមេរិក) ឱ្យខ្លួន ក្រោយមកនៅអំឡុងខែមីនា ឆ្នាំ២០២១ គាត់ក៏បានទិញរថយន្តមួយគ្រឿងម៉ាក KIA MORNING ពាក់ផ្លាកលេខភ្នំពេញ 2BK-7753 តែដាក់ឈ្មោះគាត់ជាកម្មសិទ្ធិមិនដាក់ឈ្មោះខ្លួនឡើយ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ [redacted] ប៊ុនស្រ៊ី ពិតជាបានបបួលខ្លួនឱ្យជូនគាត់ទៅស្រោចទឹកក្នុងគោលបំណងខ្លួនទៅប្រព្រឹត្តផ្លូវភេទម្តងទៀត តែត្រូវបានអាក់ខានទៅវិញនៅពេលដែលម្តាយរបស់របស់ខ្លួនទូរស័ព្ទទៅរកខ្លួន តែខ្លួនមិនបានលើកទូរស័ព្ទដោយសារតែឈ្មោះ [redacted] ប៊ុនស្រ៊ី ហាមមិនឱ្យលើក ហើយគាត់បានប្រាប់ថាបើម្តាយសួរនាំរឿងទៅខាងក្រៅនេះគឺ ឱ្យបានប្រាប់ថានៅជាមួយខ្លួន រួចក៏ដឹកខ្លួនត្រឡប់មកផ្ទះវិញ ទើបបានម្តាយរបស់ខ្លួនឱ្យខ្លួនប្រាប់តាមត្រង់កុំលាក់លៀមក្នុងរឿងនេះ លុះដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ ខ្លួនបានខ្សឹបប្រាប់រឿងរ៉ាវដែលឈ្មោះ [redacted] ប៊ុនស្រ៊ី មានបំណងមិនល្អមកលើខ្លួនដោយគាត់ធ្លាប់បានថើប, បបោសអង្អែល និងស្ទាបប្រដាប់ភេទខ្លួនច្រើនដងមកហើយ ហើយដល់ថ្ងៃទីចាប់ខ្លួនឈ្មោះ [redacted] ប៊ុនស្រ៊ី ខ្លួនក៏បានប្រាប់រឿងលម្អិតដែលឈ្មោះនេះបានធ្វើសកម្មភាពរំលោភសេពសន្ថវៈមកលើខ្លួនកន្លងមក។

-ជនត្រូវចោទឈ្មោះ [redacted] **ប៊ុនស្រ៊ី** បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈលើឈ្មោះ [redacted] **មុន្នីនាថ** ដូចការប្តឹងនោះទេ។

-តាមលទ្ធផលកោសលវិច័យឯកសារពិនិត្យការរំលោភផ្លូវភេទ លេខ៣២/២១ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ បានពិនិត្យលើសន្ទះព្រហ្មចារីជនរងគ្រោះឈ្មោះ [redacted] មុន្នីនាថ បានបញ្ជាក់ថាគ្មានស្នាមដាច់ឬរហែកទេ។

## យល់ឃើញថា

១.ជនត្រូវចោទឈ្មោះ [redacted] **ប៊ុនស្រ៊ី** ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដើម្បីស៊ើបសួរពីបទ **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនល្មើស** ជាបទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៤០ នៃក្រមព្រហ្មទណ្ឌ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២១២ អ.យ.ឃ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

២.តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] **មុន្នីនាថ** ដែលបានឆ្លើយនៅក្នុងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយនៅតំណាក់កាលស៊ើបសួរប្រហាក់ប្រហែលគ្នាដែលមានខ្លឹមសារថា៖ កាលពីថ្ងៃមិនចាំខែតុលា ឆ្នាំ២០១៩ វេលាម៉ោង០១យប់ ឈ្មោះ [redacted] ប៊ុនស្រ៊ីដែលត្រូវជាឪពុកចុងពិតជាបានធ្វើសកម្មភាពចាប់រំលោភមកលើខ្លួនដោយមិនពាក់ស្រោមប្រាកដមែន នៅពេលដែលម្តាយខ្លួនទៅខេត្តសៀមរាប ហើយបានសន្យាថានឹងទិញខ្សែករ និងរថយន្តឱ្យខ្លួន ប៉ុន្តែលុះដល់អំឡុងចុងឆ្នាំ២០២០ ទើបគាត់បានទិញខ្សែករមួយខ្សែ ៧០០USD(ប្រាំពីររយដុល្លារអាមេរិក) ឱ្យខ្លួន ក្រោយមកនៅអំឡុងខែមីនា ឆ្នាំ២០២១ គាត់ក៏បានទិញរថយន្តមួយគ្រឿងម៉ាក KIA MORNING ពាក់ផ្លាកលេខភ្នំពេញ 2BK-7753 តែដាក់ឈ្មោះគាត់ជាកម្មសិទ្ធិមិនដាក់ឈ្មោះខ្លួនឡើយ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ ឡេង ប៊ុនស្រ៊ី ពិតជាបានបបួលខ្លួនឱ្យជូនគាត់ទៅស្រោចទឹកក្នុងគោលបំណងខ្លួនទៅប្រព្រឹត្តផ្លូវភេទម្តងទៀត តែត្រូវបានអាក់ខានទៅវិញនៅពេលដែលម្តាយរបស់របស់ខ្លួនទូរស័ព្ទទៅរកខ្លួន តែខ្លួនមិនបានលើកទូរស័ព្ទដោយសារតែឈ្មោះ [redacted] ប៊ុនស្រ៊ី ហាមមិនឱ្យលើក ហើយគាត់បានប្រាប់ថាបើម្តាយសួរនាំរឿងទៅខាងក្រៅនេះគឺ ឱ្យបានប្រាប់ថានៅជាមួយខ្លួន រួចក៏ដឹកខ្លួនត្រឡប់មកផ្ទះវិញ ទើបបានម្តាយរបស់ខ្លួនឱ្យខ្លួនប្រាប់តាមត្រង់កុំលាក់លៀមក្នុងរឿងនេះ លុះដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ ខ្លួនបានប្រាប់រឿងរ៉ាវដែលឈ្មោះ [redacted] ប៊ុនស្រ៊ី មានបំណងមិនល្អមកលើខ្លួនដោយគាត់ធ្លាប់បានថើប, បបោសអង្អែល និងស្ទាបប្រដាប់ភេទ

ខ្លួនច្រើនដងមកហើយ ហើយដល់ថ្ងៃចាប់ខ្លួនឈ្មោ[redacted]ប៊ុនស្រ៊ី ខ្លួនក៏បានប្រាប់រឿងលម្អិតដែលឈ្មោះនេះបានធ្វើសកម្មភាពរំលោភសេពសន្ថវៈមកលើខ្លួនកន្លងមក។

៣.តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ប៊ុនស្រ៊ី ដែលបានឆ្លើយនៅក្នុងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌, ចម្លើយដំណាក់កាលស៊ើបសួរ ប្រហាក់ប្រហែលគ្នាដែលមានខ្លឹមសារថា៖ចំពោះពាក្យបណ្ដឹង ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់ឈ្មោះ ឡេង មុន្នីនាថ ត្រូវជាកូនស្រីចុងរបស់ខ្លួន ដែលបានចោទប្រកាន់ខ្លួនថាធ្វើសកម្មភាពរំលោភសេពសន្ថវៈមកលើខ្លួននោះគឺ ខ្លួនសុំបដិសេធចោលទាំងស្រុងដោយសារតែខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ហើយនៅអំឡុងខែតុលា ឆ្នាំ២០១៩ ខ្លួនមិនបានដឹងថាឈ្មោះ [redacted] ពុទ្ធីប៊ី ទៅខេត្តសៀមរាបដោយទុកឱ្យខ្លួន និងកូនស្រីចុងនោះនៅផ្ទះតែពីរនាក់នោះទេ ហើយកន្លងមកខ្លួនតែងតែឱ្យកូនស្រីចុងនេះទៅតាមម្ដាយជានិច្ច មិនឱ្យនៅជាមួយខ្លួនឡើយ ម្យ៉ាងវិញទៀតខ្លួនក៏មានការងាររវល់ចេញទៅខាងក្រៅផ្ទះដែរ កន្លងមកខ្លួន និងប្រពន្ធ [redacted] ពុទ្ធប៊ី ធ្លាប់មានរកាំរកូសនៅក្នុងគ្រួសារជាច្រើនលើកច្រើនសារ លុះដល់អំឡុងពាក់កណ្ដាលឆ្នាំ២០១៩ ខ្លួនបានដាក់ពាក្យបណ្ដឹងសុំលែងលះពីគាត់ដោយសារគាត់តែងតែដើរលេងខាងក្រៅជាមួយកូនស្រី ហេតុនេះការរស់នៅមិនចុះសម្រុងនឹងគ្នា លុះដល់អំឡុងចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០ ខ្លួនទទួលបានសាលក្រមស្ដាពរលែងលះ តែឈ្មោះ [redacted]ុទ្ធីប៊ី មិនព្រមទៅណាឡើយ ហើយព្យាយាមលួងលោមឱ្យត្រូវគ្នាវិញ ខ្លួនក៏យល់ព្រមរួមរស់ជាមួយគាត់រហូតដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១ ខ្លួន និងគាត់ក៏បានចុះសំបុត្រអាពាហ៍ពិពាហ៍ម្ដងទៀត តែយ៉ាងណាគាត់ និងខ្លួននៅតែមានបញ្ហាជាមួយគ្នាដដែល ដោយសារតែគាត់ចង់បានតែសំបុត្រអាពាហ៍ពិពាហ៍ថ្មី ដើម្បីលុបសាលក្រមលែងលះដែលមានការបែងចែកទ្រព្យសម្បត្តិតែប៉ុណ្ណោះ។

៤.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ពុទ្ធីប៊ី ជាម្ដាយបង្កើតរបស់ឈ្មោះ [redacted] មុន្នីនាថ ដែលបានឆ្លើយនៅក្នុងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយនៅតំណាក់កាលស៊ើបសួរប្រហាក់ប្រហែលគ្នាដែលមានខ្លឹមសារថា៖ ខ្លួនបានរួមរស់ជាមួយឈ្មោះ [redacted] ប៊ុនស្រ៊ី ជាប្ដីទី២ តាំងពីដើមឆ្នាំ២០១៣ រហូតដល់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ ទើបខ្លួន និងគាត់បានចុះសំបុត្រអាពាហ៍ ពិពាហ៍ជាផ្លូវការតាមរយៈសំបុត្រអាពាហ៍ពិពាហ៍លេខ១០៤ ចុះហត្ថលេខាដោយលោក [redacted] ចៅសង្កាត់អូរបែកក្អម និងជាមន្ត្រីអត្រានុកូលដ្ឋាន ដោយពួកខ្លួនពុំមានកូនបង្កើតជាមួយគ្នានោះទេ ដោយឡែកចំពោះកូនចំនួន០៥នាក់ គឺខ្លួនមានជាមួយប្ដីមុនតែប៉ុណ្ណោះ មូលហេតុដែលនាំឱ្យខ្លួនចុះសំបុត្រអាពាហ៍ពិពាហ៍នេះ គឺដោយសារតែគាត់លួងលោម និងសន្យាជាមួយខ្លួនថាសុខចិត្តឈប់ទាក់ទងជាមួយស្រីក្រោយរបស់គាត់ឈ្មោះ [redacted] ធារី ហៅម៉ាលី ដូចមានក្នុងរូបថត និងកិនភាគក្នុងសំណុំរឿងស្រាប់ មួយវិញទៀតការចុះសំបុត្រអាពាហ៍ពិពាហ៍នេះ គឺដោយសារពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ មុននឹងធ្វើកិច្ចព្រមព្រៀងក៏ដូចការចេញសាលក្រមនេះគឺ នៅអំឡុងខែតុលា ឆ្នាំ២០១៩ ឈ្មោះ [redacted]នស្រ៊ី បានទាញយកកាំភ្លើងខ្លី ដែលសមត្ថកិច្ចកងរាជអាវុធហត្ថរាជធានីភ្នំពេញ នឹងដកហូតក្នុងពេលចុះចាប់ខ្លួនជាក់ស្ដែង កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ ដូចមានក្នុងរូបថត និងកំណត់ហេតុប្រគល់ និងទទួល ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១១ និង១៥នាទី របស់សមត្ថកិច្ចចេញពីចង្កេះខោយកមកដាក់លើតុទុកគម្រាមកំហែងប៉ុនប៉ងសម្លាប់ខ្លួន និងឱ្យខ្លួនយកកិច្ចព្រមព្រៀងខាងលើនេះយកទៅដាក់នៅតុលាការក្នុងរឿងលែងលះ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ កូនស្រីរបស់ខ្លួនឈ្មោះ [redacted]ុន្នីនាថ បានលួចប្រាប់ខ្លួនថាកន្លងមកឈ្មោះ [redacted] ប៊ុនស្រ៊ី មានបំណងមិនល្អមកលើខ្លួនដោយធ្លាប់បានថើប,បបោសអង្អែល និងស្ទាបប្រដាប់ភេទវាជាច្រើនដងកន្លងមកហើយ ហើយជាក់ស្ដែងនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ម្សិលមិញនេះឈ្មោះនេះ ក៏បានបបួលវាទៅស្រោចទឹកក្នុងគោលបំណងប្រព្រឹត្តផ្លូវភេទម្ដងទៀត តែត្រូវបានអាក់ខានទៅវិញនៅពេលដែលខ្លួនទូរស័ព្ទទៅរកកូនស្រីតែវាមិនលើទូរស័ព្ទរបស់ខ្លួនដោយសារតែឈ្មោះ [redacted] ប៊ុនស្រ៊ី ហាមមិនឱ្យលើក ប្រើម្ដាយសួរនាំឡើងចេញ

ទៅក្រៅនេះ វាក៏បានប្រាប់ថានៅជាមួយកូនស្រីខ្លួន វាក៏បានត្រឡប់មកផ្ទះវិញ ទើបបានជាខ្លួនសួរ និងឱ្យវាប្រាប់តាមត្រង់ កុំឱ្យលាក់លៀមក្នុងរឿងនេះ វាក៏បានប្រាប់រឿងរ៉ាវដែលគាត់បានប្រព្រឹត្តលើវាកន្លងមក ហើយដល់ថ្ងៃចាប់ខ្លួនគាត់បាន ទើបកូនស្រីរបស់ខ្លួនបានប្រាប់លម្អិតថា កាលពីថ្ងៃមិនចាំ ខែតុលា ឆ្នាំ២០១៩ នៅពេលដែលខ្លួនទៅខេត្តសៀមរាប ឈ្មោះ [redacted] ប៊ុនស្រី បានហៅកូនស្រីរបស់ខ្លួនឱ្យទៅដេកក្នុងបន្ទប់ជាមួយគាត់គ្រាន់បានជាគ្នា រួចនៅយប់នោះក៏បានធ្វើសកម្មភាព ចាប់រំលោភសេពសន្ថវៈលើកូនស្រីរបស់ខ្លួនបានសម្រេចចំនួន០១លើក ដោយមិនពាក់ស្រោម ហើយជននេះបានគម្រាម កំហែងថានឹងសម្លាប់វា និងក្រុមគ្រួសារចោលបើហ៊ាននិយាយប្រាប់អ្នកដទៃ និងបានល្បួងលោមដោយសន្យាទិញខ្សែករ និងទិញរថយន្តឱ្យកូនស្រីខ្លួន ក្រោយមកជាក់ស្តែងជននេះក៏បានទិញខ្សែក ចំនួន០១ខ្សែ តម្លៃ៧០០USD(ប្រាំពីររយដុល្លាអាមេរិក) និងឡានមួយគ្រឿងម៉ាក KIA MORNINIG ពាក់ផ្លាកលេខ 2BK-7753 ឱ្យកូនស្រីរបស់ខ្លួន ដោយដាក់ឈ្មោះ គាត់ជាកម្មសិទ្ធ មិនដាក់ឈ្មោះកូនស្រីខ្លួនឡើយ ដូច្នេះខ្លួនអាចសន្និដ្ឋា និងកំណត់ក្នុងចិត្តថាឈ្មោះ [redacted] ប៊ុនស្រី ពិតជាបានប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈលើកូនស្រីខ្លួនពិតប្រាកដមែន ព្រោះមួយរយៈចុងក្រោយនេះគាត់តែងតែរករឿងខ្លួនរហូតដល់ថ្ងៃដែល សមត្ថកិច្ចកងរាជអាវុធហត្ថរាជធានីភ្នំពេញ ចុះជួយរំដោះនិងស្រាវជ្រាវចាប់ខ្លួនឈ្មោះ [redacted] ប៊ុនស្រី បានជាក់ស្តែងនៅល្ងាច ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ តែម្តង។ ក្នុងរយៈពេលដែលខ្លួនរស់នៅជាមួយឈ្មោះ [redacted] ប៊ុនស្រី គឺខ្លួនមិនដឹងថាឈ្មោះនេះមិន មែនជាមន្ត្រីឃោធាពាក់ផ្កាយបីដូចមាននៅក្នុងរូបថតជាមួយស្រីស្នេហ៍ឈ្មោះ [redacted]ារី ហៅម៉ាលី ឡើយជាក់ស្តែងនេះគឺជា អ្នករកស៊ីដូចអ្វីដែលគាត់បានឆ្លើយកន្លងមក។

៥.តាមលទ្ធផលស៊ើបសួរ ចម្លើយឈ្មោះ [redacted] មុន្នីនាថ ថាជនត្រូវចោទឈ្មោះ [redacted]ប៊ុនស្រី រំលោភខ្លួនបានសម្រេចម្តង នៅថ្ងៃទីមិនចាំក្នុងខែតុលា ឆ្នាំ២០១៩ វេលាម៉ោង០១យប់ តែគ្មានភស្តុតាងណាបញ្ជាក់ក្រៅពីចម្លើយ របស់សាម៉ីខ្លួននោះទេ។ រីឯចម្លើយជនត្រូវចោទឈ្មោះ [redacted] ប៊ុនស្រី បានឆ្លើយបដិសេធថាមិនបានរំលោភសេពសន្ថវៈ លើឈ្មោះ [redacted]ុន្នីនាថ នោះទេ។ ចម្លើយបដិសេធរបស់ជនត្រូវចោទ ចម្លើយរបស់ដើមបណ្តឹង និងចម្លើយរបស់ សាក្សី គ្មានភស្តុតាងគាំទ្រ នាំឱ្យការដាក់ជនត្រូវឈ្មោះ [redacted] ប៊ុនស្រី ក្រោមការពិនិត្យពីបទ៖**រំលោភសេពសន្ថវៈ មានស្ថានទម្ងន់ទោសទាក់ទងនឹងជនល្មើស** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌ គឺស្ថិតក្នុងលក្ខណៈវិមតិសង្ស័យ។

៦.តាមឯកសារកោសលវិច័យពិនិត្យផ្លូវភេទលេខ៣២/២១ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់មន្ទីរពេទ្យបង្អែក រាជធានីភ្នំពេញ បានបង្ហាញថា តាមការពិនិត្យសភាពរាងកាយទូទៅ មានសភាពធម្មតា។ តាមការពិនិត្យប្រដាប់ភេទផ្នែកខាង ក្រៅឃើញថាមានសភាពធម្មតា។ដូច្នេះតាមការពិនិត្យទៅលើស្ត្រីរងគ្រោះបង្ហាញឱ្យឃើញសភាពរាងកាយទូទៅធម្មតា និង សភាពប្រដាប់ភេទផ្នែកខាងក្រៅធម្មតា ដោយគ្មានស្នាមដាច់រហែកប្រដាប់ភេទនោះទេ។

៧.**បទរំលោភសេពសន្ថវៈ** ភស្តុតាងសំខាន់គឺ កោសលវិច័យពិនិត្យផ្លូវភេទ ដែលមានបន្សល់នូវស្លាកស្នាម រហែក ឬដាច់សន្ទះព្រហ្មចារី។ តែផ្អែកតាមឯកសារពិនិត្យផ្លូវភេទលើជនរងគ្រោះ ពុំមានស្លាកស្នាម និងដាច់រហែកនោះទេ អាចបញ្ជាក់ថាគ្មានការរួមភេទនោះឡើយ។

៨.តាមមាត្រា៣៨ កថាខណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ ដល់ជនជាប់ចោទ។

៩.ធាតុផ្សំសត្យានុម័ត៖នៅក្នុងបទល្មើសនេះ ធាតុផ្សំសត្យានុម័ត ដែលចាំបាច់ក្នុងការបង្កើតបទល្មើស **រំលោភ សេពសន្ថវៈ** គឺគ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែល ប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ សារការប្រើអំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង

## ហេតុដូច្នេះសម្រេច

១.លើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ [redacted] ម៉ិនស្រ៊ី ភេទប្រុស អាយុ៥៦ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) **ពីបទរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនល្មើស**. ប្រព្រឹត្តនៅចំណុចផ្ទះលេខ៤៩ ផ្លូវលំ ភូមិត្រពាំងឈូក ក្រុម២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទីមិនចាំ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល០១ និង០០ នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៤០ នៃក្រមព្រហ្មទណ្ឌ។

តាមមាត្រា២៤៧ ថ្មីនៃច្បាប់ស្តីពីវិសោធកម្មមាត្រា២៤៧,មាត្រា៣៦៨,មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.បញ្ចប់ការឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ [redacted] ម៉ិនស្រ៊ី ភេទប្រុស អាយុ៥៦ឆ្នាំ និងឱ្យដោះលែងជនត្រូវចោទឱ្យមានសេរីភាព។

លេខៈ ៣៩២ អ.យ.ឃ

ថ្ងៃ ... ខែចេត្រ ឆ្នាំខ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី 08 ខែមេសា ឆ្នាំ២០២២

ចៅក្រមស៊ើបសួរ

[redacted]

បានទទួលដំណឹង

... ខែចេត្រ ឆ្នាំខ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី ... ខែមេសា ឆ្នាំ២០២២

តំណាងអយ្យការ

[redacted]

ក្រឡាបញ្ជី

[redacted]